ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋាន
នាយកដ្ឋានព័ត៌មានវិទ្យា
Information Technology Department

# របៀបដំឡើង និងប្រើប្រាស់កម្មវិធី Telegram
# នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS

កាលបរិច្ឆេទ÷ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦
ឯកសារជំនាន់ទី ១

ការិយាល័យគោលនយោបាយនិងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងនវានុវត្តន៍

# មាតិកា

សេចក្តីផ្តើម........................................................................................................................................ 1
ក. របៀបដំឡើងកម្មវិធី Telegram នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS.................................................................... 1
ខ. របៀបបង្កើតគណនី (ចុះឈ្មោះ) ប្រើប្រាស់កម្មវិធី Telegram នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS ................................. 4
គ. របៀបប្រើប្រាស់កម្មវិធី Telegram នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS................................................................. 8
គ.១. របៀបផ្ញើសារ (Chat)............................................................................................................. 8
គ.២. របៀបផ្ញើសារទៅកាន់ក្រុម ......................................................................................................... 10
គ.៣. ការប្រើប្រាស់បញ្ជីឈ្មោះទំនាក់ទំនង (Contacts) ......................................................................... 12
គ.៥. របៀបលុបឈ្មោះទំនាក់ទំនងចេញពីបញ្ជី (Remove Contact) ........................................................... 13
គ.៦. របៀបស្វែងរកឈ្មោះទំនាក់ទំនង និងខ្លឹមសារនៅក្នុងសារ Telegram ដែលធ្លាប់បានផ្ញើកន្លងមក....................... 15
ឃ. របៀបលុបកម្មវិធី Telegram នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS .................................................................. 16

## សេចក្តីផ្តើម

កម្មវិធី Telegram គឺជាកម្មវិធីមួយប្រើប្រាស់សម្រាប់ផ្ញើសារអេឡិចត្រូនិក រូបភាព សម្លេង វីដេអូ ជាដើម ប្រកបដោយភាពរហ័សទាន់ចិត្ត សុវត្ថិភាព ងាយស្រួលប្រើប្រាស់ និងមិនមានគិតថ្លៃ។ លោកអ្នក អាចប្រើប្រាស់កម្មវិធីនេះបាននៅលើម៉ាស៊ីនកុំព្យូទ័រ ទូរស័ព្ទដៃ និងឧបករណ៍ឆ្លាតវៃផ្សេងៗ (iPAD, Tablet ជាដើម)។

លក្ខណៈពិសេសរបស់កម្មវិធី Telegram គឺអាចផ្ញើឯកសារបានគ្រប់ប្រភេទ (ឯកសារការិយាល័យគ្រប់ប្រភេទ - Word, Excel, PowerPoint, PDF ឯកសារកំសាន្តផ្សេង - វីដេអូ, ចម្រៀង និងឯកសារផ្សេងទៀត) ក្នុងទំហំធំគឺរហូតដល់ ១,៥ ជីកាបៃ (1.5 GB) ក្នុង ១ឯកសារ និងមានល្បឿនលឿនប្រៀបធៀបទៅនឹងកម្មវិធីផ្សេងៗទៀត ហើយឯកសារទាំងនោះបានរក្សាទុកនៅក្នុងបច្ចេកវិទ្យាពពកផងដែរ (Cloud Technology)។

កម្មវិធី Telegram ប្រកាសដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ដែលមានទីស្នាក់ការកណ្តាលនៅរដ្ឋធានីប៊ែរឡាំង ប្រទេសអាឡឺម៉ង់។ កម្មវិធីនេះមិនអាចប្រើប្រាស់ដើម្បីសន្ទនាជាសម្លេងផ្ទាល់ (Call) ដូចកម្មវិធី Skype ឬ Facebook Messenger នោះទេ គឺវាអាចត្រឹមតែបញ្ជូនសម្លេងទៅវិញទៅមកតែប៉ុណ្ណោះ។

### ក.របៀបដំឡើងកម្មវិធី Telegram នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS

ផ្តើមចេញពីផ្ទាំងដំបូង (Home screen) នៅក្នុងទូរស័ព្ទដៃ ឬ iPAD របស់លោកអ្នកស្រដៀងនឹងរូបខាងក្រោម។



**<u>ជំហានទី១</u>**÷ ចុចចូលកម្មវិធី App Store




**<u>ជំហានទី២</u>**÷ វាយពាក្យ telegram នៅក្នុងប្រអប់ស្វែងរក (ដូចរូបខាងក្រោម) រួចចុចប៊ូតុង “Search”



**<u>ជំហានទី៣</u>÷** ពិនិត្យរកមើលកម្មវិធី Telegram Messenger បន្ទាប់មក ទី១. ចុចលើប៊ូតុងតូចមួយឈ្មោះ “Get” ដែលនៅជាប់នឹងកម្មវិធី Telegram Messenger ( ដូចក្នុងរូបខាងក្រោម) ទី២. ចុចប៊ូតុង “INSTALL APP” ដើម្បីទាញយកដំឡើងកម្មវិធី ។






បន្ទាប់មកលោកអ្នកនឹងឃើញសញ្ញាវឌ្ឍនភាពនៃការដំឡើងកម្មវិធី Telegram រហូតដល់ចប់ ចេញពាក្យថា “Open”។ ចុងបញ្ចប់លោកអ្នកអាចរកមើលរូបសញ្ញា (Icon) កម្មវិធី Telegram នៅលើទូរស័ព្ទដៃ ឬ iPAD ដូចរូបខាងក្រោម។




**ខ.របៀបបង្កើតគណនី (ចុះឈ្មោះ) ប្រើប្រាស់កម្មវិធី** Telegram **នៅក្នុងប្រព័ន្ធប្រតិបត្តិការ** iOS

**ជំហានទី១÷** ចុចលើរូបសញ្ញា (Icon) របស់កម្មវិធី Telegram ដូចរូបខាងក្រោម



**<u>ជំហានទី២</u>÷** ចុចនៅលើពាក្យ Start Messaging




**<u>ជំហានទី៣</u>÷**

**ទី១.** ជ្រើសរើស Country (ឈ្មោះប្រទេស) ជា Cambodia

**ទី២.** បញ្ចូលលេខទូរស័ព្ទដៃផ្ទាល់ខ្លួនរបស់លោកអ្នកដែលកំពុងប្រើប្រាស់

**ទី៣.** ចុច Next



បន្ទាប់ពីចុច Next លោកអ្នកនឹងឃើញសារមួយសួរបញ្ជាក់ថាលេខទូរស័ព្ទបញ្ចូលខាងលើត្រឹមត្រូវឬ រួចចុចប៊ូតុង “OK”។ ទូរស័ព្ទដៃរបស់លោកអ្នកនឹងទទួលបានសារមួយផ្ញើចូលមកដោយមានលេខកូដសម្ងាត់ក្នុងនោះ។

**<u>ជំហានទី៤</u>÷** វាយបញ្ចូលលេខកូដដែលទទួលបានពីសារក្នុងទូរស័ព្ទដៃ រួចចុច Next




**<u>ជំហានទី៥</u>÷** ទី១. ចុះឈ្មោះរបស់អ្នក (នាមត្រកូល និងនាមខ្លួន) និង ទី២. ដាក់រូបថត (ដោយចុចនៅលើរង្វង់មូល “add photo” រួចជ្រើសរើសរូបភាពក្នុងទូរស័ព្ទដៃ ឬថតថ្មី)



ទី៣. បន្ទាប់ពីបញ្ចូលឈ្មោះនិងដាក់រូបថតរួចរាល់ ចុច Next ដើម្បីបន្ត




បន្ទាប់មកលោកអ្នកនឹងឃើញផ្ទាំងមួយដូចខាងក្រោមដែលបង្ហាញថាអាចចាប់ផ្តើមប្រើប្រាស់ Telegram បានហើយ។







<u>Telegram លើ iPAD</u>

<u>Telegram លើ iPhone</u>

## គ.របៀបប្រើប្រាស់កម្មវិធី Telegram នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS

### គ.១.របៀបផ្ញើសារ (Chat)

ផ្ដើមចេញពីផ្ទាំងខាងក្រោម ដែលជាផ្ទាំងផ្ញើសារ (Chat)៖




១. បញ្ជាក់ថាយើងកំពុងស្ថិតនៅលើផ្ទៃផ្ញើសារ (Chat)

២. ចុចរូប ដើម្បីបង្កើតសារថ្មីផ្ញើទៅកាន់នរណាមួយ (ដូចបង្ហាញក្នុងរូបខាងក្រោម)




នៅក្នុងផ្ទៃ Contacts នឹងបង្ហាញឈ្មោះសម្រាប់ទំនាក់ទំនងទាំងឡាយណាដែលមានលេខទូរស័ព្ទដៃនៅក្នុងទូរស័ព្ទដៃ ឬ iPad របស់លោកអ្នក និងចុះឈ្មោះប្រើប្រាស់កម្មវិធី Telegram រួចហើយ។

១. ជ្រើសរើសឈ្មោះមួយដើម្បីផ្ញើសារទៅកាន់ (ផ្ទាំងមួយបង្ហាញដូចខាងក្រោម)



១. បង្ហាញឈ្មោះដែលយើងបានជ្រើសរើសដើម្បីផ្ញើសារទៅកាន់

២. វាយបញ្ចូលសារជាអក្សរដែលលោកអ្នកចង់ផ្ញើ

៣. លោកអ្នកអាចផ្ញើសារជាសម្លេង ដោយគ្រាន់តែយកដៃចុចឱ្យជាប់នៅលើរូប រួចនិយាយពាក្យពេចន៍ដែលលោកអ្នកចង់ផ្ញើ បន្ទាប់មកព្រលែងដៃពីលើរូបខាងដើមវិញ ជាការស្រេច

៤. លោកអ្នកអាចផ្ញើជារូបភាព ចម្រៀង វីដេអូ ឯកសារផ្សេងៗទៀតជាច្រើនតាមរយៈចុចលើរូប (រូបខាងក្រោម)




១. ជ្រើសរើសរូបភាព ឬវីដេអូដែលមានស្រាប់នៅក្នុងទូរស័ព្ទដៃ ឬ iPAD របស់លោកអ្នកដើម្បីផ្ញើចេញ

២. ជ្រើសរើសឯកសារ (File) ដែលផ្សេងៗ

៣. ផ្ញើទីតាំងនៅលើផែនទីដែលយើងកំពុងស្ថិតនៅ

៤. ផ្ញើលេខទូរស័ព្ទទំនាក់ទំនងរបស់នរណាម្នាក់ដែលយើងមាននៅក្នុងបញ្ជីឈ្មោះទំនាក់ទំនង (Contact List)

គ. ២. <u>របៀបផ្ញើសារទៅកាន់ក្រុម</u>

យើងអាចបង្កើតជាក្រុម ដែលអាចមើល និងស្តាប់សារដែលផ្ញើក្នុងក្រុមនោះបានទាំងអស់គ្នា។ ផ្តើមចេញពីការចុចលើរូប លោកអ្នកអាចនឹងបង្កើតក្រុមបាន ដូចរូបខាងក្រោម÷




១. ចុចលើ “New Group” បន្ទាប់មកជ្រើសរើសឈ្មោះដែលត្រូវដាក់បញ្ចូលទៅក្នុងក្រុម (ដូចរូបខាងក្រោម)÷




១. ជ្រើសរើសឈ្មោះដែលត្រូវដាក់នៅក្នុងក្រុម

២. រួចចុច “Next” បន្ទាប់មកដាក់ឈ្មោះក្រុមដូចរូបខាងក្រោម




១. ដាក់ឈ្មោះក្រុម

២. ដាក់រូបថតក្រុម

៣. បញ្ជីឈ្មោះទំនាក់ទំនងនីមួយៗនៅក្នុងក្រុមដែលបានជ្រើសរើសពីខាងដើម

៤. ចុច “Create” ដើម្បីបញ្ចប់ការបង្កើតក្រុមផ្ញើសារ

៥. បន្ទាប់មកលោកអ្នក អាចធ្វើការផ្ញើសារទៅកាន់ក្រុមនោះបានដូចធម្មតា។

គ. ៣. <u>ការប្រើប្រាស់បញ្ជីឈ្មោះទំនាក់ទំនង (Contacts)</u>

ប្រសិនបើលោកអ្នកកំពុងប្រើលេខទូរស័ព្ទរបស់អ្នកជាលើកដំបូងនៅក្នុងកម្មវិធី Telegram លោកអ្នកនឹងមិនទាន់មានទំនាក់ទំនងផ្ញើសារទៅវិញទៅមកជាមួយនរណាម្នាក់ឡើយ។ លោកអ្នកអាចចូលទៅក្នុងបញ្ជីឈ្មោះទំនាក់ទំនង (Contacts) ដើម្បីមើលថាតើមានលេខទូរស័ព្ទណាខ្លះដែលបាននិងកំពុងប្រើប្រាស់កម្មវិធី Telegram ដូចជាលោកអ្នកដែរ ដើម្បីអាចផ្ញើសារបានភ្លាមៗ (ដូចរូបខាងក្រោម)។




១. ចុចលើ Contacts ដើម្បីចូលទៅក្នុងបញ្ជីឈ្មោះទំនាក់ទំនង

២. បញ្ជីឈ្មោះទំនាក់ទំនងទាំងអស់ដែលអាចប្រើប្រាស់ Telegram ផ្ញើសារបាន

៣. ចុចលើ “Invite Friends” ដើម្បីផ្ញើសារទៅកាន់ទូរស័ព្ទដៃរបស់អ្នកដែលមិនទាន់មានប្រើប្រាស់កម្មវិធី Telegram

## គ. ៤. ការប្រើប្រាស់ Setting




តាមរយៈការប្រើប្រាស់ Setting យើងអាចធ្វើការផ្លាស់ប្តូររូបថត ប្តូរឈ្មោះ ប្តូរផ្ទៃខាងក្រោយ ចាកចេញពី Telegram ជាដើម។

១. អាចប្តូររូបថត

២. អាចប្តូរឈ្មោះ

៣. ចុច Done ដើម្បីសម្រេចលើការផ្លាស់ប្តូរខាងលើ

៤. អាចចាកចេញពីកម្មវិធី Telegram

## គ. ៥. របៀបលុបឈ្មោះទំនាក់ទំនងចេញពីបញ្ជី (Remove Contact)

ជំហានទី១ ÷ ចូលទៅក្នុងបញ្ជីទំនាក់ទំនង (Contacts) រួចជ្រើសរើសនូវឈ្មោះណាមួយដើម្បីលុប



ជំហានទី២÷ ចុចចូលលម្អិតទៅក្នុងឈ្មោះទំនាក់ទំនងដែលបានជ្រើសរើសខាងលើ

១. ចុចលើ Contact

២. ចុចលើ Edit ( ផ្ទាំងមួយនឹងបង្ហាញឡើងបន្ត)




ជំហានទី៣÷ ចុចលើប៊ូតុង “Delete Contact” នៅផ្នែកខាងក្រោមនៃផ្ទាំងព័ត៌មានលម្អិតដែលបង្ហាញឡើង




សារបញ្ជាក់មួយ (Confirm) ដើម្បីសួរបញ្ជាក់យើងចុងក្រោយមុននឹងលុប ដូចខាងក្រោម÷




ចុចលើប៊ូតុង “Delete Contact” ថ្មីម្តងទៀតដើម្បីសម្រេចថាលុបចេញ។

គ.៦. <u>របៀបស្វែងរកឈ្មោះទំនាក់ទំនង និងខ្លឹមសារនៅក្នុងសារ Telegram ដែលធ្លាប់បានផ្ញើកន្លងមក</u>

ទាំងការស្វែងរកឈ្មោះទំនាក់ទំនង និងទាំងការស្វែងរកខ្លឹមសារនៅក្នុងអត្ថបទសារដែលយើងធ្លាប់បានផ្ញើសារឆ្លើយឆ្លងកន្លងមក គឺប្រើប្រាស់ប្រអប់ស្វែងរករួមគ្នា។



១. ចុចចូលទៅផ្នែក Chats

២.វាយឈ្មោះ ឬពាក្យដែលចង់ស្វែងរកក្នុងការសន្ទនាកន្លងមកនៅក្នុងប្រអប់ស្វែងរក (ក្នុងករណីលោកអ្នករកមិនឃើញប្រអប់ស្វែងរក “Search Box” ទេ លោកអ្នកអាចយកម្រាមដៃអូសនៅលើអេក្រង់ចុះក្រោមបន្តិច)

៣. បន្ទាប់មកលោកអ្នកនឹងឃើញលទ្ធផលនៃការស្វែងរក

## ឃ.របៀបលុបកម្មវិធី Telegram នៅក្នុងប្រព័ន្ធប្រតិបត្តិការ iOS

**<u>ជំហានទី១</u>÷** ចុចសង្កត់ទៅលើរូប Icon Telegram ដែលមាននៅលើផ្ទៃ Screen របស់ iPad ឬទូរស័ព្ទឱ្យជាប់




បន្ទាប់មកលោកអ្នកនឹងឃើញសញ្ញាខ្វែងមួយលេចឡើងនៅលើរូបសញ្ញាកម្មវិធី Telegram ដូចរូបខាងក្រោម

**<u>ជំហានទី២</u>÷** ចុចលើសញ្ញាខ្វែងដូចរូបខាងលើ ដើម្បីលុបកម្មវិធី Telegram ចេញពីទូរស័ព្ទ ឬ iPAD របស់អ្នក។

